BMI0016

# សម្ភាសន៍ជាមួយឈ្មោះ ភួន ធី ភេទស្រី អាយុ៥៣ឆ្នាំ

មុខងាររជំនាន់ខ្មែរក្រហម“នារីកងចល័ត”

មុខងារបច្ចុប្បន្ន“កសិករ”

ស្រុកកំណើតនៅភូមិគោកធ្នង់ ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបាត់ដំបង

រស់នៅភូមិត្រសេកជ្រុំ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ សោម ប៊ុនថន

០០:៤០:១១

២២ទំព័រ

ប៊ុនថនៈ ចឹងជាដំបូងខ្ញុំចង់សម្ភាសន៍មីង?

ធីៈ ចាស ។

ប៊ុនថនៈ ចង់ថតជាសម្លេងអ្នកមីង?

ធីៈ ចាស ។

ប៊ុនថនៈ ចឹងមីងអនុញ្ញាតឲ្យថតទេ?

ធីៈ ចាស ។

ប៊ុនថនៈ ចឹងជាដំបូងហ្នឹងខ្ញុំចង់សួរឈ្មោះអ្នកមីង អ្នកមីងឈ្មោះអីវិញ?

ធីៈ ខ្ញុំឈ្មោះធី ។

ប៊ុនថនៈ អ្នកមីងអាយុប៉ុន្មានហើយ?

ធីៈ ខ្ញុំអាយុ៥៣ឆ្នាំហើយ ។

ប៊ុនថនៈ អ្នកមីងរស់នៅក្នុងភូមិឃុំស្រុកអីដែរ?

ធីៈ ស្រុកហ្នឹង ។

ប៊ុនថនៈ ស្រុកឥឡូវ?

ធីៈ ស្រុកឥឡូវខ្ញុំនៅស្រុកម៉ាឡៃហ្នឹង ។

ប៊ុនថនៈ ភូមិ?

ធីៈ ត្រសេកជ្រុំ ។

ប៊ុនថនៈ ឃុំ?

ធីៈ ឃុំម៉ាឡៃ ។

ប៊ុនថនៈ ចឹងពីដើមមីងរស់នៅភូមិឃុំអីដែរ?

ធីៈ ពីដើមពីសង្គមហ្នឹង ។

ប៊ុនថនៈ បាទ ។

ធីៈ ខ្ញុំនៅភ្នំធំហ្នឹងនៅឃុំអូរប្រាសាទ ។

ប៊ុនថនៈ ភូមិ?

ធីៈ កាលហ្នឹងគេដាក់ភូមិគោកធ្នង់ ។

ប៊ុនថនៈ ស្រុក?

ធីៈ មង្គលបូរី ខេត្តបាត់ដំបង ពីដើមមិញណាស់ ។

ប៊ុនថនៈ ខេត្តបាត់ដំបង?

ធីៈ ចាស ។

ប៊ុនថនៈ ចឹងមីងមានបងប្អូនប៉ុន្មាននាក់?

ធីៈ ខ្ញុំមានបងប្អូន៧នាក់ ។

ប៊ុនថនៈ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

ធីៈ មើលប្រុស៤ស្រី៣ ។

ប៊ុនថនៈ មីងមានឪពុកម្តាយ?

ធីៈ ខ្ញុំមានឪពុកម្តាយ តែឥឡូវម្តាយស្លាប់ហើយនៅតែឪពុកទេ ។

ប៊ុនថនៈ បាទ ។

ធីៈ ឪពុកចាស់ជរាហើយ ។

ប៊ុនថនៈ គាត់អាយុប៉ុន្មានហើយ?

ធីៈ ឪពុកខ្ញុំ៨១ឆ្នាំហ្នឹងហើយ ។

ប៊ុនថនៈ ហើយម្តាយ?

ធីៈ ម្តាយខ្ញុំស្លាប់ហើយ ។

ប៊ុនថនៈ ស្លាប់ឆ្នាំណាដែលមីង?

ធីៈ ស្លាប់ឆ្នាំ៨២ ។

ប៊ុនថនៈ គាត់ស្លាប់ដោយសារអី?

ធីៈ ដោយសារគាត់ឈឺហើយអត់បាយអត់អី ដល់នេះបាយហូបគាត់ហើមស្លាប់ទៅ ។

ប៊ុនថនៈ ចឹងអ្នកមីងជាកូនទីប៉ុន្មាន?

ធី: ខ្ញុំកូនទី១ ។

ប៊ុនថន: កូនបងគេ?

ធី: ចាស ។

ប៊ុនថន: មីងមានបានរៀនសូត្រអីទេ?

ធី: កាលពីដើមខ្ញុំរៀនបានថ្នាក់ទី១២ ថ្នាក់ក្រោមបំផុត ។

ប៊ុនថន: ក្រោមបំផុតគេរាប់ពីលើចុះក្រោម?

ធី: ចាស!ពីលើចុះក្រោម "ស្រះអ ស្រះ អាពីដើមហ្នឹង" យើងក្រអត់លុយមានបានរៀនអី ធ្វើស្រែធ្វើអី ។

ប៊ុនថន: បាទ ។

ធី: បើឪពុកម្ដាយអត់ ។

ប៊ុនថន: ចឹងមីងឈប់រៀនមីងធ្វើអីទៀតមីង?

ធី: ធ្វើស្រែចំការជាមួយឪពុក ធ្វើស្រែជាមួយឪពុកម្ដាយ ។

ប៊ុនថន: ចឹងអ្នកមីងក្រៅពីធ្វើស្រែហ្នឹងអ្នកមីងមានធ្វើអីទៀតទេ?

ធី: អត់មានធ្វើអីផង ។

ប៊ុនថន: ចឹងរហូតដល់ឆ្នាំណាបានមីងចូលកង?

ធី: កងចល័ត ។

ប៊ុនថន: បាទៗ! ។

ធី: ឆ្នាំ៧៦ ។

ប៊ុនថន: ៧៦?

ធី: ចាស!នៅជាមួយឪពុកម្ដាយតាំងពីនេះមកដល់ឆ្នាំ៧៦បានបែកពីឪពុកម្ដាយ ។

ប៊ុនថន: បែកមកធ្វើកងចល័តនៅណាវិញ?

ធី: នៅនិមិត្តកូនដីរយើងនេះ ។

ប៊ុនថន: បាទ!កូនដីរផ្លូវបត់ចូលមកហ្នឹងអ្នកមីង?

ធី: ចាស!នៅហ្នឹងឡើងប៉ុន្មានឆ្នាំរហូតដល់ឆ្នាំ៧៩ ។

ប៊ុនថន: ឆ្នាំ៧៩?

ធី: ចាស!បានរត់ពីហ្នឹងមក មកនៅភូមិដូងយើងនេះ ។

ប៊ុនថន: នៅភូមិដូងមីង?

ធី: ចាស ។

ប៊ុនថន៖ មកកាលហ្នឹងមានគ្នាច្រើនទេ?

ធី៖ មានគ្នាច្រើន ចុះនារីច្រើនណាស់កាលហ្នឹងនោះមកមុនដំបូងមក ។

ប៊ុនថន៖ បាទ ។

ធី៖ មកនៅភូមិដូងយើងហ្នឹង នៅកងដឹកជញ្ជូនយើងហ្នឹង ។

ប៊ុនថន៖ ចឹងបងប្អូនឪពុកម្ដាយមីង?

ធី៖ ឪពុកម្ដាយនៅស្រុកទាំងអស់ ។

ប៊ុនថន៖ ចឹងមកតែមីងទេ?

ធី៖ ចាស!បែកតែខ្ញុំទេ ។

ប៊ុនថន៖ ចឹងយ៉ាងម៉េចបានជាមីងរត់មកតែម្នាក់ឯង?

ធី៖ កាលហ្នឹងនៅកងចល័តនោះដល់ហើយយួនចូលមក គេដេញ ។

ប៊ុនថន៖ បាទ ។

ធី៖ គេដេញពួកខ្ញុំរត់ទៅនោះវិញអស់ហើយទៅស្រុកតែគេដេញមកវិញ គេគៀមកវិញណាស់ ។

ប៊ុនថន៖ បាទ ។

ធី៖ ដល់គៀមកវិញហើយឲ្យខ្ញុំចូលមកកងដឹកជញ្ជូន ។

ប៊ុនថន៖ ចូលខាងដឹកជញ្ជូន?

ធី៖ ចាស!ដឹកជញ្ជូនគ្រាប់ដឹកជញ្ជូនអង្ករ ។

ប៊ុនថន៖ ចឹងកាលមីងមកនៅដំបូងហ្នឹងមានមនុស្សអីនៅទេ?

ធី៖ មាន មានតែពួកយើងរត់មកនេះ អត់មានប្រជាជនទេចាស ។

ប៊ុនថន៖ បាទ ។

ធី៖ មានតែពួកនារីទាំងកងៗ មកច្រើនមកនៅនេះគ្មានអីទេមានតែព្រៃឫស្សីព្រៃអីហ្នឹង ។

ប៊ុនថន៖ ចឹងមានដើមឈើអីទេ?

ធី៖ មានដើមឈើធំៗក៏មានព្រៃឫស្សីក៏មានសុទ្ធតែព្រៃ ព្រៃខ្លាអីហ្នឹង ។

ប៊ុនថន៖ សុទ្ធតែព្រៃ?

ធី៖ ចាសៗ!ព្រៃទាំងអស់ហ្នឹង យើងត្រួសត្រាយដូចថានារីហ្នឹងយប់ត្រង់ណាសម្រាកត្រង់ហ្នឹង ចងអង្រឹងសម្រាកត្រង់លហ្នឹង ខោអាវម្នាក់មួយកាតាប មានតែពីរបង្ហាស់ផ្លាសប្ដូរគ្មានស្អីទេ មានតែអង្រឹងមួយយប់ឡើងសម្រាកហ្នឹង យើងចេះតែមកៗមិនដឹងជាទៅណា យើងឡប់ទៅវិញចឹងគេដេញមកវិញ ។

ប៊ុនថន៖ បាទ ។

ធី៖ កាលសម័យហ្នឹង ។

ប៊ុនថន៖ បាទ ។

ធី៖ កាលហ្នឹងគេគៀមកវិញហើយយើងចេះតែមកតាមគេចឹងទៅ យើងចេះតែនៅៗដល់សព្វថ្ងៃហ្នឹង ។

ប៊ុនថន៖ បាទ!តាំងពី៧៩មក?

ធី៖ ចាស ។

ប៊ុនថន៖ ចឹងនិយាយថាកាលមីងមកហ្នឹងមកទាំងកងនារីនិងបុរសមកជាមួយគ្នា?

ធី៖ ចាស!មកទាំងអស់ ។

ប៊ុនថន៖ ប្រហែលជាប៉ុន្មាននាក់អកមីង?

ធី៖ កាលហ្នឹងច្រើនដែលហ្នឹងរាប់ពាន់នាក់ ។

ប៊ុនថន៖ បាទ ។

ធី៖ មួយវរៈសេនាធំមិនប៉ុន្មានទេ កាលហ្នឹង ។

ប៊ុនថន៖ កាលហ្នឹងមីងចូលខាងដឹកជញ្ជូនឲ្យទាហានមែនទេ?

ធី៖ ដឹកជញ្ជូនខាងទាហាន ។

ប៊ុនថន៖ នៅទាហានហ្នឹងខាងកងអី?

ធី៖ ពួកខ្ញុំខាងដឹកជញ្ជូនហ្នឹង ខ្ញុំភ្លេចអស់ហើយកាលហ្នឹង ។

ប៊ុនថន៖ ចឹងកាលមីងមកនៅចឹងយើងធ្វើផ្ទះអីខ្លួនឯង?

ធី៖ ផ្ទះហ្នឹងអត់ទេ ។

ប៊ុនថន៖ អត់ទេ កាលមីងមកដល់ដំបូង?

ធី៖ មានផ្ទះអីទេកាលហ្នឹង នៅក្រោមដើមឈើគ្របកៅស៊ូដាក់ទៅ ។

ប៊ុនថន៖ បាទ ។

ធី៖ ចុះមិនដឹងជាទៅណា បើយើងរស់នៅក្នុងរបបគេចឹង ចេះតែគោរពរបបគេចឹងទៅណាស់ ។

ប៊ុនថន៖ បាទ ។

ធី៖ យើងចេះតែគោរពគេចឹងទៅ យើងមិនដឹងជាទៅណាមកណាហើយមកតែខ្លួនមួយទៀត ឪពុកម្ដាយនៅផ្ទះទាំងអស់ ចេះតែរស់នៅជាគេទៅដល់ពេលឆ្នាំ៨១ខ្ញុំមានគ្រួសារទៅ ។

ប៊ុនថន៖ បាទ ។

ធីៈ	កាលមានគ្រួសារហ្នឹងគេចាប់ដៃគ្នាទេណាស់ កាលសម័យហ្នឹង ។

ប៊ុនថនៈ	បាទ ។

ធីៈ	ខ្ញុំមានគ្រួសារកាលឆ្នាំ៨១ហ្នឹង ។

ប៊ុនថនៈ	កាលមីងមានគ្រួសារហ្នឹងមីងអាយុប៉ុន្មានហើយ?

ធីៈ	ខ្ញុំអាយុ២០ជាងហើយកាលហ្នឹង២៦-២៧ហើយកាលហ្នឹង ។

ប៊ុនថនៈ	ចឹងមីងធំដែលហើយ?

ធីៈ	ចាស ។

ប៊ុនថនៈ	ចឹងគ្រួសារអ្នកមីងធ្វើអីកាលហ្នឹង?

ធីៈ	កាលហ្នឹងគាត់ធ្វើជាទាហាន ។

ប៊ុនថនៈ	តែមុនការហ្នឹងមីងមានស្គាល់គ្នាហើយនៅ?

ធីៈ	ខ្ញុំមិនដែលស្គាល់ផង ដើរពីក្រោយខ្ញុំតែខ្ញុំមិនដែលស្គាល់ផង ខ្ញុំមិនដឹងខ្លួនដើរពីក្រោយខ្ញុំមិនដែលស្គាល់ទេ ។

ប៊ុនថនៈ	ចឹងពេលដែលរៀបហ្នឹងបានជួបមុខគ្នា?

ធីៈ	ចាស!ជិតបៀបហ្នឹងស្គាល់គ្នាហើយ ។

ប៊ុនថនៈ	បាទ ។

ធីៈ	គេស្គាល់ខ្ញុំតែខ្ញុំមិនបានស្គាល់គេ ។

ប៊ុនថនៈ	ចឹងមុនរៀបបានស្គាល់គ្នា?

ធីៈ	ចាស!មុនដំបូងមិនស្គាល់ទេដែលសួរនេះមិនស្គាល់ទេ ដល់ចាប់ផ្តើមជិតការហ្នឹងបានស្គាល់គ្នា ។

ប៊ុនថនៈ	បាទ ។

ធីៈ	ស្គាល់គ្នាចាប់ដៃយកគ្នាកាលជំនាន់ហ្នឹង ។

ប៊ុនថនៈ	តែមីងស្រឡាញ់គាត់ដែរ?

ធីៈ	កាលហ្នឹងមិនដឹងជាពឹងពីណា ដូចថាយើងបែកពីឪពុកម្តាយមិនមានអ្នកទីពឹងណាស់ ។

ប៊ុនថនៈ	បាទ ។

ធីៈ	យើងកាលហ្នឹងនឹកឃើញបើឃើអីមានពីណាពឹង បានប្តីទៅពឹងប្តីឃើញមានគេឈឺស្លាប់តាមផ្លូវអីចឹងនឹកឃើញចឹងយកទៅបានប្តីជួយ ។

ប៊ុនថនៈ	បាទ ។

ធីៈ	ខ្ញុំមានបងប្អូនណា ។

ប៊ុនថនៈ បាទ ។

ធីៈ យកប្តីដើម្បីពឹងប្តីចឹងទៅ ដល់ហើយខ្ញុំកាត់ចិត្តយកទៅ ។

ប៊ុនថនៈ បាទ ។

ធីៈ យើងយកគេរៀបឲ្យទៅ ឆ្នាំ៨១ហ្នឹងគេរៀបទៅ ។

ប៊ុនថនៈ បាទ ។

ធីៈ កាលឆ្នាំ៨១ហើយខ្ញុំមានកូនប្រុសមួយបងគេនោះ ។

ប៊ុនថនៈ ចឹងគ្រួសារមីងមានស្រុកកំណើតនៅណាដែរ?

ធីៈ គាត់នៅខាងនោះខាងតាកែវនោះ ។

ប៊ុនថនៈ ចឹងនៅពេលដែលមីងការហើយហ្នឹងមីងនៅខាងដីកជញ្ជូនដដែលហ្នឹងមីង?

ធីៈ អត់ទេ យើងការហើយគេឲ្យយើងនៅផ្សេងហើយដោយឡែក ។

ប៊ុនថនៈ បាទ ។

ធីៈ ចេញពីដីកជញ្ជូនមកនៅជាមួយមីង១ យើងក្រុមគ្រួសារគេទៀតផ្សេង ដាក់ដោយឡែកពីដីកជញ្ជូនហើយ ។

ប៊ុនថនៈ ចឹងមីងចេញពីដីកជញ្ជូននៅពេលរៀបគ្រួសារហើយ?

ធីៈ ចាស ។

ប៊ុនថនៈ ចឹងប្តីអ្នកមីងគាត់នៅធ្វើការដដែល?

ធីៈ ចាស ។

ប៊ុនថនៈ ចឹងពេលរៀបការហើយហ្នឹងមីងរៀបផ្ទះនៅផ្សេង?

ធីៈ ចាស!កាលហ្នឹងធ្វើកូនផ្ទះៗតូចៗនៅទៅ ផ្ទះបីម៉ែតបួនជ្រុងអីនៅហ្នឹង មានគ្រួសារគេបែកពីទ័ពអីចឹង ។

ប៊ុនថនៈ ចឹងមីងធ្វើផ្ទះហើយមានគេចែកដីឲ្យនៅទេ?

ធីៈ អត់មានទេ ។

ប៊ុនថនៈ ធ្វើជាប់ៗគ្នាហ្នឹងអ្នកមីង?

ធីៈ ចាស!យើងនៅត្រង់ណានៅទៅ យើងចង់នៅត្រង់ណានៅទៅ ។

ប៊ុនថនៈ ចឹងនៅពេលហូបចុកអីអ្នកមីង?

ធីៈ ហូបចុកបើកអង្ករឲ្យ គេបើកអង្ករបើខ្វាញ់ បើក«ខ» បើករបស់អីឲ្យ ។

ប៊ុនថនៈ បាទ ។

ធីៈ ហើយបើកឲ្យហ្នឹងបើប្តីយើងទៅមុខគេបើកឲ្យតែប្តីយើងមិនទៅមុខគេមិនបើកឲ្យទេ យើង

វានផ្ទៃពោះអី ជួនកាលសម្រាលកូនអីក៏មិនជួយគួកកន្ទបអីដែរ ។

ប៊ុនថន: បាទ ។

ធី: ជួនកាលមកទាន់ជួនកាលអត់ទៅ ។

ប៊ុនថន: បាទ ។

ធី: បើយើងមិនទៅចឹងគេផ្ដាច់របប ។

ប៊ុនថន: ចឹងបើផ្ដាច់របបបានអីគិតគូជីវភាព?

ធី: អត់ យើងត្រូវតែទៅទោះបីមានផ្ទៃពោះគ្រប់ខែយ៉ាងណាក៏ត្រូវតែទៅដែរ ព្រោះអីយើងគោរពគេ ។

ប៊ុនថន: បាទ!ចឹងមីងមានទំនាក់ទំនងទៅម្ដាយដែលព្រោះនៅជិតហ្នឹងដែរ?

ធី: ទោះបីនៅជិតនេះក៏អត់ដឹងដែរ ។

ប៊ុនថន: បាទ ។

ធី: ទាល់តែជិតផ្ដាច់ខ្លួនបានដឹងដំណឹងឪពុកម្ដាយ កាលផ្ដាច់ខ្លួនស្រួលទៅឪពុកខ្ញុំមករកខ្ញុំមុន ។

ប៊ុនថន: បាទ ។

ធី: ដល់ចេញមកហ្នឹងគេចាប់ផងអីផង ចេញទៅវិញគេដេញចាប់គាត់គេចោទថាគាត់មកទាក់ទងខាងនេះ ។

ប៊ុនថន: បាទ ។

ធី: កាលសម័យគេមិនទាន់ផ្ដាច់ខ្លួនគេដេញចាប់គាត់ យ៉ាប់ណាស់ បើឪពុកក្មេងខ្ញុំទៅពួកនៅខាងចាប់ដាក់គុកយើងនៅស្វាយនោះ គុកអីត្រង់ណាទេកន្លែងស្វាយហ្នឹង ចាប់ដាក់គុកប៉ុន្មានថ្ងៃ ។

ប៊ុនថន: ចឹងនិយាយទៅទៅវិញទៅមកពិបាក?

ធី: ចាស!ពិបាកណាស់កាលមិនទាន់ផ្ដាច់ខ្លួនហ្នឹង ឪពុកខ្ញុំគាត់លួចមកជួបខ្ញុំ ។

ប៊ុនថន: បាទ ។

ធី: ហើយគាត់ទៅវិញទៅ ។

ប៊ុនថន: តែមីងមិនដែលទៅជួបគាត់ទេ?

ធី: មិនហ៊ានទៅទេ ព្រោះអីខ្លាចខាងនោះដែរ ។

ប៊ុនថន: ចឹងអត់មានដែលសរសេរសំបុត្រអីទៅទេ?

ធី: មិនដែលទំនាក់ទំនងអីបានទេ តែឪពុកម្ដាយគាត់នឹកកូនគាត់ចេះតែលួចមកទៅណាស់ ។

ប៊ុនថន: បាទ ។

ធីៈ		កាលហ្នឹងមកដល់ជិតផ្ទះខ្ញុំហើយហ្នឹង ដូចថាជិះអាឡានធំហើយជាប់ផុងគាត់គេងនៅហ្នឹង មួយយប់ទាល់ភ្លឺគាត់មិនដឹងផ្ទះខ្ញុំនៅជិតហ្នឹងណាផ្ទះខ្ញុំតូចនោះ ។

ប៊ុនថនៈ		បាទ ។

ធីៈ		ហើយដល់ពេលនេះទៅជាប់ដល់ភ្លឺបានឃើញថា ប្អូនខ្ញុំមកឃើញប្អូនខ្ញុំគាត់ស្គាល់ថាគាត់ ដេកនៅហ្នឹងមួយយប់ហើយមួសខាំចង់ងាប់មករកកូនឡានជាប់ផុងជិតផ្ទះតែមិនដឹង ចុះ មិនស្គាល់ឪពុកស្គាល់កូនកាលនោះ ។

ប៊ុនថនៈ		បែកគ្នាយូរ?

ធីៈ		ចាស!ដល់មើលចុះមើលឡើងបានដឹងថាឪពុកឯង ។

ប៊ុនថនៈ		ប្អូនមីងហ្នឹងជាប្អូនថ្លៃឬប្អូនបង្កើត?

ធីៈ		ប្អូនបង្កើត?

ប៊ុនថនៈ		ចឹងកាលមកហ្នឹងមកជាមួយប្អូន?

ធីៈ		ចាស!ប្អូនស្រីមករកខ្ញុំ ។

ប៊ុនថនៈ		តែប្អូនហ្នឹងមានចំណាំមីងទេ?

ធីៈ		អត់ចំណាំទេ ដល់មកខ្ញុំឃើញពុកខ្ញុំដល់ហើយទំនាក់ទំនងស្គាល់ឪពុកខ្ញុំបានដឹងថាប្អូន តែ កាលខ្ញុំចេញមកប្អូនខ្ញុំទាបតូច ។

ប៊ុនថនៈ		បាទ ។

ធីៈ		ឥឡូវវាមកវាក្រមុំបាត់ហើយ ។

ប៊ុនថនៈ		កាលគាត់មកចូលហ្នឹងនៅឆ្នាំណាមីង?

ធីៈ		មកដឹងឆ្នាំណា ។

ប៊ុនថនៈ		៩០ជាង?

ធីៈ		ចាស!៩២អីហ្នឹង ។

ប៊ុនថនៈ		ចឹង១០ជាងហើយ?

ធីៈ		១០ឆ្នាំជាងហើយ ។

ប៊ុនថនៈ		ចឹងមីងអាចរៀបរាប់កាលឆ្នាំ៧៥មីង?

ធីៈ		៧៥ ។

ប៊ុនថនៈ		បាទ!និយាយថា៧៥ហ្នឹងមីងនិងឪពុកម្ដាយមីងនៅក្នុងភូមិហ្នឹងមានបែងចែកជាកងជាអីទេ មីង?

ធីៈ		អត់មានទេ នៅក្នុងភូមិនៅជាមួយឪពុកម្ដាយ ។

ប៊ុនថន៖ បាទ ។

ធី៖ ឪពុកម្ដាយខ្ញុំកាលហ្នឹងអត់មានបាយទឹកម្ដាយខ្ញុំនៅកាលហ្នឹងមិនទាន់ស្លាប់ទេណាស់ ។

ប៊ុនថន៖ បាទ ។

ធី៖ គេជម្លៀសខ្ញុំទៅនៅអូរស្វួតទេណាស់ ។

ប៊ុនថន៖ នៅអូរស្វួត?

ធី៖ ចាស! ចេញពីភូមិគោកធ្នង់ទៅអូរស្វួត ។

ប៊ុនថន៖ បាទ ។

ធី៖ នៅអូរស្វួតអត់បាយអត់ទឹក ម៉ែខ្ញុំអត់បាយហូប កាលហ្នឹងម៉ែខ្ញុំគាត់នៅខាងកាស៊ីនបាយណាស់ គាត់លួចអង្ករដាក់ក្នុងហោប៉ៅ គាត់លួចអង្ករយកមកឲ្យខ្ញុំហូប"យំ..." ។

ប៊ុនថន៖ ចឹងកាលការហើយហ្នឹងមីងនៅហ្នឹងរហូតមីង?

ធី៖ ចាស ។

ប៊ុនថន៖ ចឹងរាល់ថ្ងៃមីងមានកូនប៉ុន្មានហើយ?

ធី៖ ខ្ញុំមានកូន៣ ។

ប៊ុនថន៖ កូនបីនាក់?

ធី៖ ចាស ។

ប៊ុនថន៖ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

ធី៖ ប្រុសបងមួយស្រីពីរ ។

ប៊ុនថន៖ តែមានបានរៀនបានអីទេ?

ធី៖ កូនខ្ញុំអាបងថ្នាក់ទី៥ ។

ប៊ុនថន៖ តូចៗហ្នឹង?

ធី៖ មានប្ដីកូនមួយហើយតើ អាបងនោះកូនពីរ ។

ប៊ុនថន៖ ចឹងមានគ្រួសារប៉ុន្មាននាក់ដែរ?

ធី៖ មានអស់ហើយនៅតែមួយទេ ទៅថៃបាត់ហើយកូនពៅ ។

ប៊ុនថន៖ តែបានរៀនទាំងអស់គ្នា?

ធី៖ ចាស! មីតូចនេះពីដើមថ្នាក់ទី៩ចូលថ្នាក់ទី១០ខ្ញុំអត់ពេកឈប់រៀនទៅ ។

ប៊ុនថន៖ តែបានរៀនបានចេះអានចេះសរសេរ?

ធី៖ ចាស! ចេះមើលដាច់ ។

ប៊ុនថន៖ មីងរាល់ថ្ងៃហ្នឹងប្រកបមុខរបបរអីដែរ?

ធី៖		ខ្ញុំលក់បបរ ។

ប៊ុនថន៖	លក់ពេលព្រឹក?

ធី៖		លក់ពេលព្រឹកអស់ហើយអស់តាំងពីម៉ោង៨ ។

ប៊ុនថន៖	ចឹងគ្រួសារអ្នកមីង?

ធី៖		ខ្ញុំលែងគ្នាបាត់ហើយ លែងគ្នាពីរទៅបីឆ្នាំហើយ ។

ប៊ុនថន៖	ចឹងខ្ញុំចង់សួរមីងបន្តទៅទៀត ខ្ញុំចង់ដឹងពីស្ថានភាពនៅស្រុកម៉ាឡៃហ្នឹងមីង?

ធី៖		ចាស ។

ប៊ុនថន៖	ចឹងកាលមីងមកដល់ដំបូងហ្នឹងជាព្រៃតែម្ដង?

ធី៖		ចាស ។

ប៊ុនថន៖	ចឹងឆ្នាំណាបានគេបង្កើតជាភូមិអីចឹង?

ធី៖		កើតជាភូមិហ្នឹងមិនដឹងជាឆ្នាំ៨០ ប៉ុន្មានទេ តែភូមិមាននេះចេះតែគ្រួសៗប្រឡោះផ្ទះ ។

ប៊ុនថន៖	បាទ ។

ធី៖		មួយផ្ទះៗទៅហើយខ្ញុំជម្លៀសទៅដល់ដីថៃគេហៅ៨៥ នោះ ។

ប៊ុនថន៖	បាទ ។

ធី៖		មកពីហ្នឹងហើយមកនៅនេះ ។

ប៊ុនថន៖	បាទ ។

ធី៖		ឆ្នាំ៩១-៩២ចឹងហើយនៅចាប់ដីនៅតាមហ្នឹងទៅ ។

ប៊ុនថន៖	បាទ ។

ធី៖		មុនដំបូងធ្វើផ្ទះតូចៗហ្នឹង ហើយមើលទៅបែបលែងទៅណាហើយបានចាប់ដីធ្វើធំទៅ ចឹងបានមានផ្ទះធំៗហ្នឹង ។

ប៊ុនថន៖	បាទ ។

ធី៖		មានឈើធ្វើផ្ទះដល់សព្វថ្ងៃនេះ ។

ប៊ុនថន៖	មីងមានផ្ទះធំ?

ធី៖		ចាស!កាលហ្នឹងឈើវាច្រើនសុទ្ធតែព្រៃនោះអាខ្លួនឯង ។

ប៊ុនថន៖	ចឹងអាខ្លួនឯង?

ធី៖		ចាស!អាខ្លួនឯង ។

ប៊ុនថន៖	ចឹងដល់ពេលធ្វើធ្វើជួលគេ?

ធី៖		ចាស!ជួលគេ ។

ប៊ុនថន៖	ចឹងកាលមីងមករត់ចូលថៃទៀតមីង?

ធី៖	អត់ទេ កាលនេះយើងនៅនេះដែលនៅតូចកាលដែលយួនវ៉ៃ គេជម្លៀសទៅនៅដីថៃទាំងអស់ ។

ប៊ុនថន៖	បាទ ។

ធី៖	ស្រុកថៃទាំងអស់ នៅស្រុកថៃហើយដល់ពេលយួនដកទៅហើយបានគេយកយើងមកវិញ ដឹកមកដាក់នេះបានមកនៅរហូតមក ។

ប៊ុនថន៖	ចឹងកាលហ្នឹងវៀតណាមវ៉ៃចូលដល់ណាដែរ?

ធី៖	វ៉ៃមកដល់ហ្នឹងសុទ្ធតែផ្លូវរណ្ដៅទាំងអស់ ដល់ភ្នំគេហៅវត្ត៩៣នេះជិតនេះ ។

ប៊ុនថន៖	បោះទីតាំងនៅហ្នឹង?

ធី៖	ចាស ។

ប៊ុនថន៖	ចឹងខាងខ្មែរក្រហម?

ធី៖	ខ្មែរក្រហមនៅខាងព្រំដែនទៅ ។

ប៊ុនថន៖	ចឹងបាញ់គ្នាទៅវិញទៅមក?

ធី៖	ចាស!បាញ់គ្នាកាលហ្នឹង កាលហ្នឹងហើយដែលខ្ញុំថាអ្នកមានគ្រួសារពោះធំអីហ្នឹង គេយកគ្រួសារមកច្បាំងទៅ យើងសម្រាលកូនអីតែឯងទៅណាស់ ។

ប៊ុនថន៖	បាទ ។

ធី៖	ប្ដីនៅមុខចឹងទៅគេបើកអង្ករកាលជំនាន់ហ្នឹង ។

ប៊ុនថន៖	បាទ ។

ធី៖	កាលនោះគេវ៉ៃខ្លាំងដែរ គេជម្លៀសប្រពន្ធឲ្យទៅនៅដីថៃហើយពួកទ័ពៗនៅព្រំដែនចឹងទៅ បើយើងមិនមកជួយការពារគេ គេផ្ដាច់ ។

ប៊ុនថន៖	បាទ ។

ធី៖	គេផ្ដាច់របបមិនឲ្យជាអង្ករអីទេ ។

ប៊ុនថន៖	ចឹងកាលវ៉ៃទៅវិញទៅមកចឹងមានស្លាប់មានអីទេមីង?

ធី៖	មានខ្លះអត់ខ្លះ ។

ប៊ុនថន៖	ចឹងវៀតណាមអត់មានដែលចូលដល់ព្រំដែនទេ?

ធី៖	អត់ដែលចូលទេ ។

ប៊ុនថន៖	មីងថៃស្ដាប់មិន.....?

ធី៖	ខ្ញុំនៅបានមួយឆ្នាំហើយដឹង ធ្វើផ្ទះតូចៗនៅ ។

ប៊ុនថនៈ ចឹងកាលហ្នឹងគេអនុញ្ញាតឲ្យនៅដែរ?

ធីៈ ចាស!យើងនៅជាមួយថៃ មានភូមិខ្មែរនៅមួយកន្លែងចឹងទៅ ។

ប៊ុនថនៈ គេហៅអីវិញ?

ធីៈ កាលហ្នឹងគេហៅ៨៥ ។

ប៊ុនថនៈ ចឹងកាលហ្នឹងគេអត់មានដាក់ឈ្មោះភូមិអីទេ?

ធីៈ អត់ទេ គេដាក់ថា៨៥ ។

ប៊ុនថនៈ នៅស្រុកអីវិញមីង?

ធីៈ អត់ស្គាល់ ។

ប៊ុនថនៈ ចឹងនៅម្តុំហ្នឹងសុទ្ធតែខ្មែរនៅទាំងអស់?

ធីៈ ខ្មែរនៅដោយខ្មែរទៅថៃនៅគៀនហ្នឹងដែរ ។

ប៊ុនថនៈ ប្រជាជនថៃ.....?

ធីៈ ចាស!មានស្រែគេ កូនស្រែគេធំៗប៉ុននេះឯង ស្រែគេចំការគេស្រែគេធំៗដូចផ្ទះយើង ចឹងហើយយើងទៅនៅធ្វើផ្ទះតូចៗប៉ុននេះ ។

ប៊ុនថនៈ ចឹងកាលនៅហ្នឹងអត់មានធ្វើអីទេមីង?

ធីៈ អត់មានធ្វើអីទេ នៅដីគេមានធ្វើអីណាអត់មានកូនមានចៅចឹងទៅ ទៅស៊ីឈ្នួលបេះសណ្តែកឲ្យថៃចឹងទៅ កាច់ពោតឲ្យថៃចឹងទៅ ទៅដកដំឡូងឲ្យថៃចឹងទៅ ។

ប៊ុនថនៈ ចឹងកាលនៅហ្នឹងគ្រួសារមីងឡើងវ៉ៃ?

ធីៈ ចាស ។

ប៊ុនថនៈ ចឹងនៅបានមួយឆ្នាំគេឲ្យមីងមកនៅណាវិញ?

ធីៈ មកនៅនេះវិញ ។

ប៊ុនថនៈ មកនៅភូមិដូងនេះ ?

ធីៈ ចាស!មកនៅនេះពេលដែលយួនដកថយចេញទៅគេយកយើងមកដាក់នេះ តែទាំងអស់គ្នាហ្នឹង ។

ប៊ុនថនៈ ដកថយទៅណាទៅ?

ធីៈ ដកថយទៅនៅតាមភ្នំចេះទៅ ចេះតែទៅៗៗៗ ។

ប៊ុនថនៈ ចឹងដកចេញពីនេះទៅតាមភ្នំ?

ធីៈ ចាស!គេយកគ្រួសារមកដាក់នេះទៅ គេយកប្តីៗទៅមុខអស់ទៅ ។

ប៊ុនថនៈ ចឹងនៅនេះមានខស្សរាហ៍វ៉ៃគ្នាដែលទេមីង?

ធីៈ វ៉ៃដែរ ។

ប៊ុនថនៈ ចឹងដល់វ៉ៃទៅយើងរត់ចូលដីថៃ?

ធីៈ ចាស! យើងរត់ទៅចូលអូរទៅមានថៃតិចៗរស់នៅ នៅសម្ងំក្នុងអូរចឹងទៅពេលយួនដកទៅ ឡើងមកវិញមក ។

ប៊ុនថនៈ បាទ ។

ធីៈ កាលហ្នឹងយ៉ាប់ដែរ រងគ្រាប់ផ្លោងទាំងអស់គ្នាទាំងកូនទាំងចៅ ទៅណារួចកាលហ្នឹងនោះ ទៅវិញក៏មិនហ៊ានទៅចេះតែទ្រាំនៅ ។

ប៊ុនថនៈ ចឹងមីងមានដឹងថាម៉ាឡៃហ្នឹងគេដាក់ភូមិដូងហ្នឹងតែម្ដងឬគេហៅយ៉ាងម៉េច?

ធីៈ មុនដំបូងគេហៅភូមិដូងចឹង ។

ប៊ុនថនៈ ភូមិដូងចឹង?

ធីៈ ចាស ។

ប៊ុនថនៈ ប៉ុន្តែអត់មានទាន់បែកចែកជាស្រុកទេ?

ធីៈ គេហ្នឹងគេហៅថាម៉ាឡៃៗភូមិដូង កាលហ្នឹងមិនទាន់បានបែងចែកជាឃុំត្រសេកជ្រុំអីទេ កាលហ្នឹងនោះ ។

ប៊ុនថនៈ បាទ ។

ធីៈ ភូមិឃុំចែកក្រោយមកទេ ដឹងថាភូមិដូងពីណាដឹងតែភូមិដូងដែរ មិនមានស្រុកមានអីទេ គេហៅតែម៉ាឡៃទេ ។

ប៊ុនថនៈ បាទ ។

ធីៈ ម៉ាឡៃភូមិដូងៗចឹងទៅ ហើយគេសួរថាទៅណា ទៅភូមិដូងចឹងទៅ ខ្លះហៅថាម៉ាឡៃចឹង ទៅ ។

ប៊ុនថនៈ ចឹងកន្លែងទីប្រជុំជននោះគេហៅអីដំបូង?

ធីៈ អីណាកន្លែងផ្សារហ្នឹង ។

ប៊ុនថនៈ បាទ! កន្លែងផ្សារហ្នឹង?

ធីៈ គេហៅភូមិដូងចឹងដែរ ។

ប៊ុនថនៈ ចឹងមានដឹងយ៉ាងម៉េចបានជាគេដាក់ភូមិដូងហ្នឹងមីង?

ធីៈ អត់ដឹងដែរ ឃើញថៃដាំដូងច្រើនគេដាក់ភូមិដូងចឹងទៅ ។

ប៊ុនថនៈ កន្លែងបត់ទៅព្រំដែនថៃហ្នឹង?

ធីៈ ចាស! ដីថៃហ្នឹងអាក្រឡុកហ្នឹងដូងច្រើនគេហៅភូមិដូងទៅ គេអត់ស្គាល់ចឹងគេដាក់ភូមិដូង

ទៅ ។

ប៊ុនថន៖ ចឹងគេតែហៅតៗគ្នាទៅ?

ធី៖ ចាស!ចេះហៅតៗគ្នាទៅដឹងដល់អ្នកក្នុងគេហៅភូមិដូងដែលទៅ ។

ប៊ុនថន៖ ចឹងម៉ាឡៃគេហៅតាមអីវិញមីង?

ធី៖ ម៉ាឡៃគេធ្លាប់ហៅក្នុងអីប្រជាជនយើងឪពុកម្តាយយើងពីដើមមកគេហៅម៉ាឡៃៗ ។

ប៊ុនថន៖ បាទ ។

ធី៖ តែមិនដែលឃើញទេ គេថាភ្នំម៉ាឡៃហ្នឹង ចេះតែហៅតាមគ្នាទៅ ពួកខ្ញុំមករស់នៅហ្នឹងទៅ ឃើញភ្នំម៉ាឡៃនៅនោះទេ តែមានភូមិដូងថៃហ្នឹងមានដូងច្រើននោះ ។

ប៊ុនថន៖ បាទ ។

ធី៖ មានដូងច្រើនគេហៅភូមិដូងចឹងទៅជាប់ចឹងទៅ ។

ប៊ុនថន៖ បាទ!ចុះភូមិផ្សេងៗទៀតដូចជាភូមិបឹងបេងអី អាហ្នឹងគេហៅតាមអីវិញ?

ធី៖ អត់មានផង ។

ប៊ុនថន៖ ឃុំបឹងបេង?

ធី៖ កាលហ្នឹងមានដើមបេងធំ ។

ប៊ុនថន៖ ចឹងដាក់ឈ្មោះតាមចឹង?

ធី៖ ចាស!មានដើមបេងធំៗហើយមួយបឹងនោះសុទ្ធតែដើមបេង ។

ប៊ុនថន៖ ចឹងក្នុងបឹងហ្នឹងសុទ្ធតែដើមបេងទាំងអស់?

ធី៖ ចាស!ហើយគេដាកបឹងបេងចឹងទៅ ។

ប៊ុនថន៖ បាទ ។

ធី៖ ហើយគីឡូ៩អីវាឆ្ងាយដែលគេហៅគីឡូ៩ចឹងទៅ ។

ប៊ុនថន៖ គីឡូ៩នៅណាវិញ?

ធី៖ ហួសបឹងបេងទៅណាទៀតនោះ ទៅនេះដីថៃ ទៅនោះវិញ ។

ប៊ុនថន៖ បាទ!ទៅផុតទៀតបុកទៅសំពៅលូនហ្នឹង?

ធី៖ ចាស!បឹងបេងហ្នឹងទៅខាងសំពៅលូនវិញគីឡូ១២គីឡូ១៣នោះ ។

ប៊ុនថន៖ ចឹងគីឡូ១២គីឡូ១៣ហ្នឹងនៅដីខ្មែរមិនមែនដីថៃ?

ធី៖ ដីខ្មែរមិនមែនដីថៃទេ ។

ប៊ុនថន៖ ចឹងមកបង្កើតជាភូមិហ្នឹងមីងមានដឹងថាបង្កើតនៅពេលណាដែលអ្នកមីង?

ធី៖ ខ្ញុំអត់មានបានចាំអីផង ។

ប៊ុនថន៖ ក្រោយសមាហរណ៍កម្មឬមួយក៏មុនមីង?

ធី៖ ក្រោយ ។

ប៊ុនថន៖ ក្រោយសមាហរណ៍កម្ម?

ធី៖ ចាស ។

ប៊ុនថន៖ ចឹងមីងមានដឹងថាម៉ាឡៃហ្នឹងនៅស្រុកអីវិញមីង ដំបូងគេតាំងពីឆ្នាំ៧៩មីងមកដល់?

ធី៖ អត់ដឹងអីផង ។

ប៊ុនថន៖ អត់ដឹងនៅក្នុងស្រុកអីទេ?

ធី៖ ចាស!ដឹងតែមកដល់ម៉ាឡៃហ្នឹង ដល់ផ្ដាច់ខ្លួនហើយបានដឹងថាស្រុកម៉ាឡៃគេដាក់ស្រុកមានភូមិអីបណ្ដោយទៅ ។

ប៊ុនថន៖ ចឹងមីងថាមានស្រុកកំណើតនៅ?

ធី៖ នៅភ្នំធំ ។

ប៊ុនថន៖ នៅស្រុកភ្នំធំ?

ធី៖ នៅភូមិភ្នំធំស្រុកមង្គលបូរី ខេត្តបាត់ដំបង ។

ប៊ុនថន៖ ចឹងមីងក្រោយសមហរណ៍កម្មហើយមីងនៅហ្នឹងដដែល?

ធី៖ ចាស ។

ប៊ុនថន៖ ចឹងក្រោយសមាហរណ៍កម្មមីងហើយមីងមានរកស៊ីអីទៀតទេ?

ធី៖ ខ្ញុំអត់មានធ្វើអីផងខ្ញុំធ្វើស្រែឥឡូវអស់ស្រែហើយ ស្រែតែបន្តិចមួយរ៉ៃពីររ៉ៃហ្នឹង ។

ប៊ុនថន៖ ចឹងដីស្រែគេចែកឲ្យ?

ធី៖ អត់ទេ ចាប់បានខ្លួនឯងម៉ារ៉ៃពីររ៉ៃដល់ពេលយើងអត់យើងលក់ទៅ គ្មានអីទេមានតែផ្ទះទេសព្វថ្ងៃនេះ លក់បបរចិញ្ចឹមខ្លួនទៅ តែកង់កញ្ចាស់មិនមានផង ។

ប៊ុនថន៖ បាទ ។

ធី៖ នេះផ្ទះដោយសារខ្លួនឯងបានលើកហ្នឹង ចុះយើងអត់មានដើមរកស៊ីយើងអត់មានលុយកាក់ ។

ប៊ុនថន៖ តែថាមានដាំសណ្ដែកដាំអីបាន?

ធី៖ ដាំសណ្ដែកគេមានចំការលុយគេធំគេមានបងប្អូនអីជួយទៅណាស់ គេមានដើមពីនេះពីនោះគេចាប់ផ្ដើមធ្វើទៅបានហើយ ។

ប៊ុនថន៖ ចឹងមានអ្នកខ្លះជួយដីគេដែរ?

ធី៖ ជួលដីគេ ខ្លះគេមានខចំការធំ គេធ្វើបានចំការច្រើនដូចថាលុយគេធំ មានខ្សែគេធ្វើធំគេ អ្នកមានលុយតែផ្តល់បន្តៗ ចែកកូនចែកចៅគេទៅណាស់ ។

ប៊ុនថន៖ បាទ ។

ធី៖ លុយគេប្រាក់ខែគេធំ គេមានខ្សែគេតាមរយៈពុកម្តាយគេផ្ញើរមកពីនេះពីនោះទិញដីទិញអីទៅ ។

ប៊ុនថន៖ បាទ ។

ធី៖ ខ្លះអត់ដូចតែគ្នាហ្នឹង អត់ដូចតែគ្នាហ្នឹងមានធ្វើអីបាន មានម៉ែឪចែកឲ្យទេពួកខ្ញុំនេះ ។

ប៊ុនថន៖ ចឹងដំបូងមានគេចែកដីយ៉ាងម៉េចដែលមីង ឬមួយយើងចាប់បានយកឬមួយចែក?

ធី៖ អាហ្នឹងពួកខ្ញុំចាប់បានយក ចាប់បានយកខ្លួនឯង ខ្ញុំចាប់បានដែលតើតែប្តីខ្ញុំដាច់ជើងទៅ ។

ប៊ុនថន៖ ដាច់ជើងដោយសារអីវិញ?

ធី៖ គាត់ទៅមុខហ្នឹងគាត់ជាន់មីន ចាប់ដីបានគាត់រវល់តែព្យាបាលជើងហ្នឹងគេយកអស់ទៅ ។

ប៊ុនថន៖ ចាប់បានច្រើនទេ?

ធី៖ ចាប់បានច្រើនដែលតើ ។

ប៊ុនថន៖ កាលពីណាគ្រាយបានប៉ុន្មានយកប៉ុណ្ណឹងទៅ?

ធី៖ ចាស!ចាប់ដូនកាលយើងគ្រាយតែព្រាំៗចឹងទៅយើងដាក់ផ្លាកចោលទៅណាស់ ។

ប៊ុនថន៖ បាទ ។

ធី៖ យើងរវល់តែទៅមើលជើងចឹងមកវិញគេយកអស់រលីង ។

ប៊ុនថន៖ ចឹងកាលគ្រាយហ្នឹងមានមីនមានអីទេ?

ធី៖ មានសុទ្ធតែមីន សុទ្ធតែដីមីនទាំងអស់ ខ្ញុំផ្សងសំណាងដូនណាគ្រាយៗទៅដាច់ជើងស្លាប់ទៅ អ្នកគ្រាយយកដីសុទ្ធតែផ្សងសំណាង ។

ប៊ុនថន៖ បាទ ។

ធី៖ មិនមានដីទំនេរសុទ្ធតែមីនទាំងអស់ ប្តីខ្ញុំហ្នឹងខ្ញុំយកគ្នាហ្នឹងគាត់ពិការលែងទៅព្យាបាលជើង ដីខ្ញុំចាប់បានច្រើនដែលគេយកបាត់អស់ទៅ គេមានលុយគេជួលកាប់យកអស់ទៅ ។

ប៊ុនថន៖ បាទ ។

ធី៖ ខ្ញុំអត់ដដែលហ្នឹង ទំរាំជាជើងគេយកដីអស់ ។

ប៊ុនថន៖ មីនហ្នឹងខាងណាជាអ្នកដាក់?

ធី៖ មីនហ្នឹងខាងក្នុងដាក់ផងខាងនេះដាក់ផង ខាងនោះចូលមកគេដាក់ទៅខាងនេះចូលមកក៏ដាក់ទៅ ។

ប៊ុនថន៖ ចឹងនៅជុំវិញម៉ាឡៃហ្នឹងសុទ្ធតែមីនជុំវិញទាំងអស់?

ធី៖ ចាស!សុទ្ធព្រៃមីនតាមផ្លូវនេះក៏មានមីនដែល ខ្ញុំកាលហ្នឹងជុតប៉ះមីនពីរគ្រាប់តែមិនផ្ទុះដែរ កាលហ្នឹង ។

ប៊ុនថន៖ មកនៅភូមិហ្នឹងមីង?

ធី៖ ចាស!កាលមកនៅដំបូងសុទ្ធតែព្រៃសុទ្ធតែមីន មីនជាន់ស្លាប់៦៩ហ្នឹង ។

ប៊ុនថន៖ ចឹងប្រជាជនមានគ្រោះថ្នាក់ច្រើនដែរ?

ធី៖ ច្រើនណាស់ដាច់ជើងមីនច្រើនណាស់ ខ្លះស្លាប់ទៅខ្លះនៅហើយដាចលជើងកំបុតជើង សុទ្ធតែត្រូវមីនខ្ញុំនៅម្តុំនេះ ។

ប៊ុនថន៖ ចឹងរាល់ថ្ងៃហ្នឹងនៅមាន?

ធី៖ នេះអត់មានទេ តែមាននៅក្រោយៗនេះ ស៊ីម៉ាក់មកដោះប៉ុន្មានថ្ងៃបានជាង១០គ្រាប់ ដែរ ។

ប៊ុនថន៖ ចឹងខាងក្រោយនេះ?

ធី៖ ខាងមាត់អូរនេះ នេះហួសរំលងបួនប្រាំផ្ទះនេះ ។

ប៊ុនថន៖ បាទ ។

ធី៖ ជួនកាលនៅជិតជើងត្រសរហ្នឹងមិនដឹងផង នៅក្រោមផ្ទះអី ។

ប៊ុនថន៖ ចឹងនិយាយរឿងដីដែលចាប់បានហ្នឹងមានធ្វើប្លង់អីទេមីង?

ធី៖ កាលហ្នឹងមិនទាន់មានធ្វើទេ នៅទាំងអស់គ្នា ។

ប៊ុនថន៖ កាលហ្នឹងយើងចាប់បានប៉ុន្មានធ្វើប៉ុណ្ណឹងទៅ?

ធី៖ ចាស ។

ប៊ុនថន៖ ចឹងកាលបានមានប្លង់ច្បាស់លាស់ទៅ?

ធី៖ មានប៉ុន្មានប្លង់ប្រហែលជា៣ឆ្នាំនេះ បីឆ្នាំបួនឆ្នាំគេចាប់ផ្តើមធ្វើប្លង់ ។

ប៊ុនថន៖ ចឹងមីងគិតថាមុនសមាហរណ៍កម្មនិងសមាហរណ៍កម្មហើយ ដូចថាជីវភាពរស់នៅយ៉ាងម៉េចដែរពិបាកឬយ៉ាងម៉េច?

ធី៖ ចំពោះខ្ញុំពិបាកដែលព្រោះមិនមានប្តីរកស៊ីចិញ្ចឹម ពិបាកណាស់ទីពឹងខ្លួនឯង លក់បបរចិញ្ចឹមទៅ ។

ប៊ុនថន៖ បាទ ។

ធី៖ បានកូនពៅទៅថៃ ។

ប៊ុនថន៖ ទៅថៃធ្វើការអីទៅ?

ធី៖ ទៅបោសសម្អាតផ្ទះឲ្យគេ ។

ប៊ុនថន៖ ស្រីក៏ប្រុស?

ធី៖ ស្រី កូនទើបអាយុ១៨ឆ្នាំ ។

ប៊ុនថន៖ ១៨?

ធី៖ ចាស!ខែ១២មកវិញហើយ ។

ប៊ុនថន៖ ទៅដល់ណាដែរ?

ធី៖ អត់ស្គាល់ដែរ ឆ្ងាយដែលហ្នឹង ។

ប៊ុនថន៖ កាលទៅហ្នឹងមានក្រដាសស្នាមអីដែរ?

ធី៖ អត់មានទេ យើងលួចទៅរកស៊ីហ្នឹង និយាយឲ្យត្រង់ទៅនៅរៀនហ្នឹងឃើញម្ដាយអត់លក់បបរអីហ្នឹងទៅជួយរកម៉ែខ្លះទៅ ។

ប៊ុនថន៖ តែឃើញទៅដែលឃើញឡានដឹកទៅថៃអីមីង?

ធី៖ ចាស!ទៅថានឹកម៉ែខែ១២មកវិញហើយ ។

ប៊ុនថន៖ ចឹងមានដែលទូរស័ព្ទមកមីងទេ?

ធី៖ ទើបតេហើយមិញហ្នឹងប្រាប់ថាខែ១២សុំមកវិញហើយម៉ែអើយ មកនៅលក់ត្រីអីក្នុងផ្សារចឹងទៅ ។

ប៊ុនថន៖ បាទ ។

ធី៖ ផ្សារថៃហ្នឹង ។

ប៊ុនថន៖ ផ្សារហ្នឹងនៅជិតផ្ទះ?

ធី៖ ចាស!លក់នៅផ្សារថៃហ្នឹងមួយថ្ងៃបាន៦០ទៅ៧០អីដែរ ។

ប៊ុនថន៖ ៧០បាត?

ធី៖ ចាស ។

ប៊ុនថន៖ ជួយលក់គេ?

ធី៖ ចាស!ជួយលក់ឲ្យថៃហ្នឹងណាស់ កាលមុនទៅហ្នឹងជួយលក់ផ្លែឈើមួយថ្ងៃ៥០មួយព្រឹកស្នាននេះមកវិញហើយ៥០បាតដែរ តែវាមិនសល់បានអស់ៗចឹងទៅ ។

ប៊ុនថន៖ បាទ ។

ធី៖ ដល់ហើយវាសុំទៅនោះម្ដងចឹងខ្ញុំក៏ឲ្យទៅៗ តែឥឡូវវាបានបីខែហើយខែ១២មកវិញហើយ ។

ប៊ុនថន៖ នៅបឹងកកប្ដូនៅណា?

ធី៖ នៅបឹងកកហ្នឹងឯង ។

ប៊ុនថន៖ ចឹងមីងចេះថៃទេ?

ធី៖ ស្តាប់បានខ្លះៗ និយាយបានមួយម៉ាត់ៗ ។

ប៊ុនថន៖ អត់ចេះសរសេរទេ?

ធី៖ អត់ចេះសរសេរទេ ។

ប៊ុនថន៖ ចឹងមីងមកនៅនេះឆ្នាំណា?

ធី៖ កាលមិនទាន់បានប្តីមកនៅនេះមួយសារ ដល់ពេលបានប្តីមកនៅមួយសារទៀតទៅនៅឆ្នាំ ៩២កាលហ្នឹង នៅរហូតមកអត់មានទៅណាទៀតទេ កាលហ្នឹងមិនទាន់ផ្តាច់ខ្លួនទេ ។

ប៊ុនថន៖ ចឹងមីងមកនៅភូមិនេះដំបូងហើយមានផ្លាស់ទៅណាទៀតទេ?

ធី៖ អត់មានទៅណាទៀតទេ ។

ប៊ុនថន៖ និយាយថាមុនពេលមានប្តីហ្នឹងមកនៅហ្នឹងម្តង?

ធី៖ នៅម្តងកាលយួនចូលមកគេជម្លៀសចេញទៅស្រុកថៃកាលហ្នឹង ទៅនៅជំរំ៨៥ហ្នឹង ។

ប៊ុនថន៖ បាទ ។

ធី៖ ដល់ពេលទៅនៅហ្នឹងយូរទៅគេឲ្យយើងមកវិញ ពេលយួនដកទៅគេឲ្យយើងមកវិញ យើងមកវិញទៅគេឲ្យយើងចាប់ដីមួយផ្ទះៗហ្នឹង យើងចាប់នៅណាចាប់ទៅស្រេចតែ យើងចាប់ ចាប់ច្រើនបានច្រើនចាប់បានតិចៗទៅណាស់ ។

ប៊ុនថន៖ បាទ ។

ធី៖ តែគេមិនទាន់ចែកជាប្លង់ជាអីទេ ។

ប៊ុនថន៖ ចាបឲ្យយកនៅ?

ធី៖ ចាស!ចាប់យកទៅ ។

ប៊ុនថន៖ ចឹងយ៉ាងម៉េចបានមិននៅជិតផ្សារ?

ធី៖ ខ្ញុំកាលមុននៅហ្នឹងដែលផ្លូវបំបែកយើងនេះ មុននៅហ្នឹងដែលតែម៉ែក្មេកខ្ញុំមកលេងអត់ មានទឹកអីហូបទេ អទ់មានអណ្តូងអីមានតែទឹកអូរនេះ ដល់ពិបាកពេកមកនៅនេះទៅ ។

ប៊ុនថន៖ អូរព្រំដែនហ្នឹង?

ធី៖ ចាស!អូរព្រំដែនហ្នឹង ក៏មកនៅនេះទៅ ។

ប៊ុនថន៖ មកនៅនេះដើម្បីជិតទឹកប្រើប្រាស់?

ធី៖ ចាស!ដល់ប្រើយូរៗទៅទឹកអូរប្រើមិនកើត វាមិនល្អក៏នាំគ្នាជីកអណ្តូង ស្តាអណ្តូងចាស់ៗ ហូបទៅ ។

ប៊ុនថន: ចឹងអណ្តូងយើងបុកចេញទេមីងយើងបូមពីក្រោមមក?

ធី: ចាស! ចេញនៅជិតអូរតែជីកអណ្តូងក្នុងអូរយកទឹមពីក្រោមមកអត់យកទឹមអូរទេ យើង ជីកចឹងទឹមវាបានល្អទឹកពីក្រោមមក ។

ប៊ុនថន: ចឹងមីងរៀបការហើយមកនៅហ្នឹងរហូត?

ធី: ចាស ។

ប៊ុនថន: ដូរពីខាងមុខមក?

ធី: ចាស ។

ប៊ុនថន: ចឹងឪពុកមីងឥឡូវនៅ?

ធី: នៅស្រុក ។

ប៊ុនថន: នៅភ្នំធំ?

ធី: ចាស ។

ប៊ុនថន: គេដាក់ស្រុកអីវិញ?

ធី: គេដាក់ស្រុកមង្គលបូរីចឹងឯង ។

ប៊ុនថន: ស្រុកមង្គលបូរី?

ធី: ចាស! ខេត្តបន្ទាយមានជ័យ ។

ប៊ុនថន: ចឹងប្អូនៗមីង?

ធី: ប្អូនខ្ញុំនៅជុំពុក មានពៅមួយទេ ទៅនៅថៃដែលរកស៊ីចិញ្ចឹមពុកដែរ ។

ប៊ុនថន: នៅជុំគ្នាហ្នឹងទាំងអស់?

ធី: ចាស! គេមានប្តីប្រពន្ធអស់ហើយនៅតែមួយទេ ពៅហ្នឹងពុកផ្ញើរនៅជាមួយប្អូនស្រីខ្ញុំ តែ ប្អូនទៅរកស៊ីចិញ្ចឹមឪពុកនៅថៃ ។

ប៊ុនថន: ចឹងមីងខស្សាហ៍ទៅលេង?

ធី: ខ្ញុំខស្សាហ៍ចេញចូលដែល ទើបអត់បានទៅពេលភ្ជុំបិណ្ឌនេះ ។

ប៊ុនថន: តែគាត់ខស្សាហ៍មកហ្នឹងដែរ?

ធី: គាត់ទៅមកដែរ តែគាត់ចាស់ហើយ គាត់ឈឺមួយថ្ងៃគាត់មួយថ្ងៃកោដែរ អាយុ៨០ចូល៨១ហើយ ។

ប៊ុនថន: គាត់នៅម៉ាំ?

ធី: គាត់ស្លាប់ម្តងហើយ កាលមិនទាន់ផ្តាច់ខ្លួនគាត់ស្លាប់បីយប់បីថ្ងៃ ។

ប៊ុនថន: អូ ។

ធីៈ ប្អូនខ្ញុំមកពីដីថៃមក មកយកខ្ញុំទៅ ។

ប៊ុនថនៈ គេហៅថាភ្ញីកហ្នឹង?

ធីៈ ចាស!បីថ្ងៃគាត់មិនទាន់ដឹងខ្លួនទេ ឥឡូវគាត់ជាគាត់ដើរមិនរួចទេ គាត់រឹងដៃជើងអស់ គាត់ងើបមិនរួចទេ បត់ជើងហ្នឹងស្នាទោស គាត់យកអាចម៍ខ្លួនគាត់ហ្នឹងគៀកខ្លួនគាត់វិញ គាត់មិនដឹងទេ ។

ប៊ុនថនៈ ដូចថាគាត់វង្វេង?

ធីៈ ចាស!គាត់វង្វេងឥឡូវគាត់ដឹងតិចៗហើយ គាត់ដើរបានគាត់ដឹងបត់ដៃបត់ជើងខ្លួនគាត់ ។

ប៊ុនថនៈ បាទ ។

ធីៈ មួយថ្ងៃជាមួយថ្ងៃឈឺទៅ មិនទៀងទាត់ទេគាត់ចាស់ហើយ ។

ប៊ុនថនៈ ចឹងមីងភូមិអីហ្នឹងនៅក្រោយសមាហរណ៍កម្មហើយគាត់រកស៊ីអីដែលអ្នកមីង?

ធីៈ ភាគច្រើនធ្វើស្រែធ្វើចំការ គេមានដើមទុនច្រើនគេធ្វើចំការ គេមានបងប្អូនគេម៉ែគេជួយមកពីនោះ មានដើមរកស៊ីចេះតែបានតៗទៅណាស់ ។

ប៊ុនថនៈ បាទ ។

ធីៈ ខ្ញុំអត់ធ្វើចំការដីស្រែក៏អត់ អត់មានទាំងអស់ ។

ប៊ុនថនៈ ភាគច្រើនធ្វើចំការ?

ធីៈ ធ្វើចំការ ស្រែមានតិចតួចទេច្រើនតែម៉ាហូបហ្នឹង ។

ប៊ុនថនៈ បាទ ។

ធីៈ មានច្រើនបំផុត៣០រ៉ៃអី ដីស្រែណាស់១០រ៉ៃខ្លះ៤រ៉ៃ៣រ៉ៃ២រ៉ៃក៏មានដែរ ភាគច្រើនធ្វើចំការ ។

ប៊ុនថនៈ បាទ ។

ធីៈ ធ្វើចំការពីដើមឡើងគេមានខ្សែធ្វើធំ គេមានចំការគេមានកូនចៅគេច្រើន កូនចៅគេជួយកាប់ទៅគេបានច្រើន ។

ប៊ុនថនៈ ចឹងអ្នកមីងមានអីចង់បន្ថែមទៀតទេ?

ធីៈ ខ្ញុំអត់មានអីផង ។

ប៊ុនថនៈ ចឹងខ្ញុំអរគុណមីងច្រើនហើយ ។

ធីៈ ចាស ។

**«ចប់»**